# មេរោគវេះណៃល
**(West Nile Virus)**

មេរោគវេះណៃល ជាមេរោគម្យ៉ាងដែលធ្វើឲ្យមនុស្សយើងធ្លាក់ខ្លួនឈឺពី គ្រុនក្តៅ ទៅជាឈឺធ្ងន់ធ្ងរ រហូតដល់រលាកខួរក្បាល ពាក្យអង់គ្លេសហៅថា Encephalitis ឬរលាកស្រោមខួរក្បាល ហៅថា Meningitis។ មេរោគនេះកើតនៅលើសត្វស្លាប ហើយឆ្លងពីមួយទៅមួយដោយសារមានមុសខាំ។ មូសដែលមានផ្ទុកមេរោគនេះ ខាំមនុស្សយើងឬសត្វ ហើយធ្វើឲ្យមនុស្ស ឬសត្វធ្លាក់ខ្លួនឈឺ។ នៅក្នុងសហរដ្ឋ គេសង្កេតឃើញមានមេរោគវេះណៃល មុនដំបូងបង្អស់ នៅក្នុងរដ្ឋញូវយ៉កកាលពីឆ្នាំ 1999។ បន្ទាប់មកវាបានរាតត្បាតពេញទាំងសហរដ្ឋតែម្តង

អ្នកដែលឆ្លងមេរោគវេះណៃលជាច្រើន ពុំមានរោគសញ្ញាអ្វីឡើយ។ តែអ្នកខ្លះទៀតអាច មានសញ្ញារោគ ដូចជាគ្រុនបន្តិចបន្តួច, ឈឺក្បាលនិងរមឹរតរាងកាយ។ ភាគច្រើន ច្រើនមានកន្ទួលលើស្បែកឬហើមកូនកណ្តុរ។ មេរោគវេះណៃល អាចធ្វើឲ្យមនុស្សមួយចំនួនតូច ដែលមានមេរោគនេះធ្លាក់ខ្លួនឈឺជាទម្ងន់ ឬឈឺរហូតដល់ស្លាប់បាត់បង់បាន។ លក្ខណៈដែលធ្ងន់ធ្ងរបំផុតអាចធ្វើឲ្យឈឺក្បាល, គ្រុនក្តៅខ្លាំង, រោយក, ធេងធោង, វង្វេងវង្វាន់, សន្លប់បាត់ស្មារតី, ញ័រដៃជើង, ប្រកាច់, ស្លាប់ដៃស្លាប់ជើង ហើយជួនកាលវាអាចបណ្តាលស្លាប់បាន។ មេរោគវេះណៃលអាចធ្វើទុក្ខដល់មនុស្សដែលមានអាយុ 50 ឡើងលើច្រើនជាងគេ។

មកទល់នឹងពេញឥឡូវនេះ ពុំទាន់មានវិធីព្យាបាលណាមួយដែលអាចព្យាបាលជម្ងឺ បណ្តាលពីមេរោគវេះណៃល បានឡើយទេ។ អ្នកដែលធ្លាក់ខ្លួនឈឺល្មមៗ អាចជាសះស្បើយវិញបានដោយខ្លួនឯង។ ប៉ុន្តែ អ្នកដែលកើតរោគនេះចំនួន 10% អាចស្លាប់បាត់បង់បាន។

ក្នុងបច្ចុប្បន្ននេះ ពុំមានថ្នាំចាក់បង្ការរោគ សំរាប់ការពាររោគវេះណៃលបានទេ។ មធ្យោបាយល្អបំផុត ក្នុងការការពារ មេរោគវេះណៃល គឺការប្រុងប្រយ័ត្នកុំឲ្យមានមូសខាំ។ រយៈពេលដែលមូសមាន មេរោគច្រើនជាងគេ គឺនៅក្នុងកំឡុងពេល ពីចុងខែកក្កដា គឺខែប្រាំពីរ ទៅទល់នឹងខែកញ្ញា គឺខែប្រាំបួន។ ប្រសិនបើលោកអ្នក រស់នៅក្នុងតំបន់ដែលមានមូសច្រើន ហើយ ដើម្បីកុំឲ្យមានមូសខាំ លោកអ្នកគួរអនុវត្តវិធីការពារ ដូចតទៅនេះ៖

- សូមកុំនៅលេងខាងក្រៅយូរពេក ជាពិសេស នៅវេលាល្ងាចប្រលុបនិងពេលព្រឹកព្រលឹម

- ប្រសិនបើ ត្រូវតែនៅក្រៅផ្ទះ លោកអ្នក គួរពាក់អាវដៃវែងនិងខោជើងវែង។ លាបថ្នាំសម្លាប់ មូសនៅលើស្បែកនិងសំលៀកបំពាក់ ទៅតាមវិធីណែនាំលើដប ឬកំប៉ុង។ ថ្នាំនេះអាចធ្វើទុកដល់ភ្នែកនិងមាត់ ដូច្នេះសូមកុំលាបលើបាតដៃក្មេងឲ្យសោះ។
- ពិនិត្យមើលបង្អួចនិងទ្វាឲ្យមានបិទសំណាញ់ឲ្យជិត កុំឲ្យមានធ្លុះធ្លាយ។

ដើម្បីការពារកុំឲ្យមានមូស លោកអ្នក គួរ៖

- យករបស់ដែលមានដក់ទឹក ដូចជាកៅស៊ូកងឡាន, កំប៉ុង, ក្រឡរឬធុងទឹកចេញពីបរិវេណផ្ទះរបស់អ្នក ដើម្បីជៀសវាងកុំឲ្យមានទឹកដែលជាហេតុអាចបង្កើតមូសបាន។
- ប្តូរទឹកសំរាប់ឲ្យសត្វស្លាបលេងមួយអាទិត្យម្តង។
- យកទឹកចេញពីលើគំរបអាងទឹកហើយសំអាតអាងទឹកដោយដាក់ជាតិខ្លរីន។

នៅក្នុងរដ្ឋម៉ាស្សាឈូសេត បុគ្គលិកប្រសូងសាធារណ៉ាសុខាភិបាល បានចាប់ប្រមូលមូសពីខែឧសភា គឺខែប្រាំ ទៅទល់នឹងរដូវស្លឹកឈើជ្រុះ យកទៅពិនិត្យមើល នៅក្នុងមន្ទីរពិសោធន៍រដ ដើម្បីរកមើលក្រែងមានមេរោគវេះណៃល, មេរោគធ្វើឲ្យខួរក្បាល និងមេរោគដទៃទៀត។ ជាមួយនេះ ក្រសួងមានវិធានការណ៍តាមដាន រកមើលសត្វស្លាបដែលស្លាប់ដើម្បីយកទៅធ្វើតែស៍មើលរកមេរោគវេះណៃល។

ចំពោះពត៌មានបន្ថែមស្តីអំពីមេរោគវេះណៃល ឬមានបំណង់ចង់រាយការណ៍អំពីសត្វស្លាបស្លាប់ សូមទូរស័ព្ទ ទៅក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត 1-866-627-7968, អាសយដ្ឋានវ៉ិបសៃ www.mass.gov/dph ឬទូរស័ព្ទ ទៅក្រសួងសុខាភិបាលប្រចាំទីក្រុងឡូវែលលេខ (978) 970-4010។

*ពត៌មាននេះដកស្រង់និងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*